| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | ចិត្តចលភាព |
| **ប្រធានបទ** | ការរីកចម្រើនរាងកាយ និងចលនា |
| **ចំណងជើងមេរៀន** | ល្បែង អង្គុយចុះដេញមេរោគ<br>(ដកស្រង់ពីសៀវភៅរឿងរឿងបិសាចចម្លែកតូចៗ) |
| **កម្រិត** | ទាប ៣០ នាទី |
| **គោលបំណង** | ប្រាប់បានពីរបៀបធ្វើចលនាតូច និងធំ នៃសកម្មភាព<br>ដើរ រត់ លោត និងវា។ |
| **បំណិនសម្បទា** | -ធ្វើចលនាដើរ រត់ លោត និងវារ ទៅតាមវិធីផ្សេងៗ។ |
| **ចរិយាសម្បទា** | អំណត់ព្យាយាម ស្វាហាប់ រហ័សរហួន ទន់ភ្លន់<br>បម្រុងប្រយ័ត្ន រង់ចាំវេន និងសប្បាយរីករាយ។ |
| **គ្រូបង្រៀន** | រៀនពីរបៀបនៃការលេងល្បែងឱ្យបានច្បាស់ជាមុនសិន |
| **កុមារ** | អង្គុយឬឈរជារង្វង់(ឬតាមវិធីផ្សេងៗទៀតក៏បាន)។ |
| **រៀបចំ** | រៀបចំកន្លែងសមរម្យសំរាប់លេង។ |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|

| | | |
|---|---|---|
| 1. ជ្រើសរើសកន្លែងសម្រាប់លេងល្បែងនោះ។<br>2. ត្រូវច្បាស់ថាក្មេងៗទាំងអស់ចេះលេងល្បែងហ្នឹង។<br>3. ពន្យល់សេចក្តីណែនាំ និងសុំក្មេង៣នាក់ដើម្បីជួយបង្ហាញក្នុងការលេងល្បែងនេះ ក្មេងៗទាំងអស់នឹងសម្តែងជាមេរោគ ។<br>4. ព្យាយាមប្រាប់ក្មេងៗឱ្យកុំឱ្យប៉ះក្មេងដដែលៗពេលដែលក្មេងៗរត់ទៅប៉ះនោះ ។<br>5. ស្រែក ‹‹ទៅ›› ដើម្បីចាប់ផ្តើមលេងល្បែងហ្នឹង ។<br>6. មួយទៀត នៅពេលដែលក្មេងទាំងអស់កំពុងលេងនោះ គ្រូត្រូវពិនិត្យក្មេងៗតើក្មេងៗធ្វើតាមសេចក្តីណែនាំឬអត់។<br>7. គ្រូត្រូវមើលឱ្យច្បាស់ថាមានក្មេងអង្គុយចុះច្រើនអត់? បើមានច្រើន ត្រូវ ស្រែកថាប៉ាវម្តងទៀតនឹងឱ្យក្មេងចាប់ផ្តើមលេងម្តងទៀត គឺជាការស្រេច។ | 1. ត្រូវច្បាស់ថាក្មេងៗទាំងអស់ចេះលេងប៉ាវស៊ីងស៊ីង<br>(ក្មេងទាំង២ចាប់ដៃគ្នាហើយនិយាយថា៖ក្តាប់លាត<br>កន្ត្រៃ ប្រសិនបើក្មេងមិនទាន់ចេះប៉ាវទេ អ្នកត្រូវពន្យល់ពួកគេពីការប៉ាងសិន។<br>ដូចជា ការប៉ាវបែបណាដែលត្រូវឈ្នះ និងត្រូវចាញ់ ក្តាប់ឈ្នះ កន្ត្រៃ កន្ត្រៃឈ្នះលាត លាតឈ្នះក្តាប់)<br>2. ក្មេងៗទាំងអស់ គឺជាមីរោគ។<br>3. នៅពេលដែលគ្រូនិយាយថា‹‹ទៅ›› ក្មេងៗទាំងអស់គួរតែរត់ជុំវិញកន្លែងលេងល្បែងហ្នឹង និងព្យាយាមប៉ះ | 1. ពួកគេគួរតែព្យាយាមប៉ះអ្នកផ្សេងឱ្យបានច្រើនដែលអាចធ្វើទៅបាន ដោយជៀសវាងឱ្យគេប៉ះខ្លួនឯងដែរ។<br>2. នៅពេលដែលអ្នកបានប៉ះអ្នកណាម្នាក់ហើយនោះ អ្នកត្រូវប៉ាវស៊ីងស៊ុង ជាមួយគេ។<br>3. ប្រសិនបើអ្នកប៉ាវឈ្នះ អ្នកអាចបន្តដេញចាប់គេបន្តទៀត។<br>4. ប្រសិនបើអ្នកចាញ់ ត្រូវអង្គុយចុះ។<br>5. ត្រូវតាមដានមើលអ្នកដែលអ្នកប៉ាវចាញ់នោះដោយយកចិត្តទុកដាក់<br>6. បើម្នាក់នោះត្រូវប៉ាវចាញ់គេវិញម្តង អ្នកអាចក្រោកឈររត់ដេញចាប់គេបានម្តងទៀត។<br>7. ព្យាយាមគេចខ្លួនពីក្មេងៗផ្សេងទៀត នៅពេលដែលអ្នករត់ដេញចាប់។ |

| | | |
|---|---|---|
| | ក្មេងៗផ្សេងទៀត។ ពួកគេគួរតែព្យាយាមប៉ះអ្នកផ្សេងឱ្យបានច្រើនដែលអាចធ្វើទៅបាន ដោយជៀសវាងឱ្យគេប៉ះខ្លួនឯងដែរ។<br>4. នៅពេលដែលក្មេងម្នាក់បានប៉ះក្មេងម្នាក់ទៀត ក្មេងៗទាំង២នោះត្រូវឈប់សិន និងត្រូវប៉ាវ ប្រសិនបើអ្នកណាប៉ាវចាញ់ត្រូវអង្គុយចុះ ហើយអ្នកដែលឈ្នះត្រូវបន្តការដេញប៉ះក្មេងផ្សេងទៀតបាន។<br>5. ក្មេងដែលចាញ់អង្គុយចុះលើស្មៅ ឬកន្លែងដែលស្អាតដោយប្រុងប្រយ័ត្ន និងត្រូវតាមដានមើលក្មេងដែលបានប៉ះ និងប៉ាវជាមួយខ្លួនឱ្យបានច្បាស់ ព្រោះថាប្រសិ | 8. នៅពេលអ្នកប៉ះបាននរណាម្នាក់ សុំប៉ហដោយមានថ្មមៗ សូមកុំរុញគេឱ្យសោះ។ |

| | | |
|---|---|---|
| | នជាក្មេងម្នាក់នោះត្រូវគេប៉ះ និងប៉ាវចាញ់គេ ហើយត្រូវអង្គុយចុះ នោះក្មេងដែលអង្គុយមុនហ្នឹង ត្រូវក្រោកឈរហើយរត់លេងបន្តទៀតបានវិញ។<br>6. ប្រសិនបើគ្រូបានឃើញក្មេងអង្គុយច្រើនពេក គ្រូអាចស្រែក«ប៉ាងស៊ីងសុង» ទាំងអស់ត្រូវក្រោកឈរ និងរត់ជុំវិញម្តងទៀត។ | |